# កិច្ចសំភាសន៍របស់លោកតាឈ្មោះ យ៉ាំម៉ា

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ យ៉ាំម៉ា

កៈ ចាសជាដំបូងសុំជំរាបសួរលោកតា!

ខៈបាទៗជំរាបសួរ!

កៈ ចាសចឹងថ្ងៃនេះចៅមានឳកាសមែនទែនដែលបានមកសំភាសន៍លោតាផ្ទាល់ចៅធ្វើការស្ម័គ្រនៅក្នុងការងារគំរោងរបស់សាលានៅ BYU ហាវ៉ៃនៅខាងសហរដ្ឋអាមេរិចហើយគំរោងមួយនឹងគេចង់ជួយចងក្រងឯកសារប្រវត្តិរបស់ប្រជាជនកម្ពុជាពង្សប្រវត្តិរបស់គាត់ អឺ....បទពិសោធន៍របស់គាត់តាំងពីក្មេងរហូតមកដល់ឥលូវនឹងសម័យបច្ចុប្បន្ននឹងថាតើគាត់មានបទពិសោធន៍អីគេខ្លះជាពិសេសសម័យដែលគាត់ធ្លាប់បានឆ្លងកាត់ពីមុនៗមកណាស់លោកតា!

ខៈ បាទ!

កៈ ចាសចឹងហើយអឺ....ចៅមានឧកាសចឹងចៅសុំអនុញ្ញាតលោកតាដើម្បីនឹង Record សំលេងរបស់លោកតាធ្វើការសំភាសន៍មួយនឹងដើម្បីដាក់នៅក្នុងវេបសាយរបស់សាលានៅខាងសហរដ្ឋអាមេរិចបានដែរឬទេលោកតា?

ខៈ បាទបានអីអត់អីទេ!

កៈ ចាសអរគុណច្រើនលោកតាចឹងថ្ងៃនេះការសំភាសន៍នឹងធ្វើឡើងនៅក្នុងថ្ងៃទី១៤ ខែ៦ ឆ្នាំ២០១៨ យើងហើយអឺ....ជាដំបូងចៅសុំជំរាបសួរលោកតាៗមានឈ្មោះអីដែរលោកតា?

ខៈ បាទខ្ញុំឈ្មោះដើម យ៉ាំម៉ា (មានសំលេងរំខានពីខាងក្រៅ) ហៅរុធ!

កៈ ចាសលោកតាហើយចុះឈ្មោះពេញរបស់លោកតាឈ្មោះអីដែរលោកតា?

ខ៖ ឈ្មោះ យ៉ុំម៉ានឹងម៉ង!

ក៖ ឈ្មោះនឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណដែរឬទេលោកតា?

ខ៖ បាននៅក្នុងអត្តសញ្ញាណប័ណ្ណនឹង(ឈ្មោះនឹងគឺត្រូវចឹងអត្តសញ្ញាណប័ណ្ណរបស់គាត់)!

ក៖
អូ...ចាសលោកតាហើយទៅឈ្មោះហៅក្រៅនឹងហេតុអីបានជាគេហៅឈ្មោះលោកតាចឹងដែរលោកតា(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ អឺ...(មានសំលេងរំខាន) ខ្ញុំៗពីដើមខ្ញុំរស់នៅស្រុកកោះធំឯណោះទេណាស់ បាទគេហៅតាម៉ាកៗនឹងហើយ(មានសំលេងរំខាន)ដល់តែមកនៅភ្នំពេញនេះវត្តភ្នំពេញនេះខ្ញុំបាទដូរឈ្មោះអាចារ្យរុធៗចឹងទៅណាស់ បាទ អាចារ្យរុធនឹង!

ក៖ ចាស ចឹងមានបានជាប់ងារនឹងរហូតមកណ៎លោកតា?

ខ៖
បាទជាប់ងារនឹងរហូតមកនៅនឹងនេះគេហៅតែអាចារ្យរុធៗចឹងទៅហើយបើទៅស្រុកហើយអត្តសញ្ញាណប័ណ្ណឈ្មោះ យ៉ុំម៉ា!

ក៖ ចាស លោកតាហើយអឺ....លោកតាឥលូវនេះលោកតាមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំឆ្នាំថ្មីនឹងអាយុ៦៥ឆ្នាំហើយ!

ក៖ ចាសលោកតាហើយអឺ....លោកតាកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ (សំលេងរំខាន)ខ្ញុំថ្ងៃខែខ្ញុំមិនបានចាំច្បាស់ទេប៉ុន្តែខ្ញុំអឺ....ចំណាំដូចថា៥៤ណាស់ ឆ្នាំ១៩៥៤(លោកតាកើតនៅឆ្នាំ១៩៥៤)!

ក៖ ចាសហើយចុះឆ្នាំខ្មែរយើងវិញដូចជាត្រូវនឹងឆ្នាំសុរិយគតិអីដូចជាឆ្នាំគោ ឆ្នាំឆ្លូវ ឆ្នាំជូតអីចឹងណាស់លោកតា?

ខ៖ ខ្ញុំនឹងកើតឆ្នាំមមី បាទគេហៅសេះណាស់បាទ ខ្ញុំកើតនៅក្នុងឆ្នាំនឹងមមីនឹង!

ក៖ ចាសលោកតាហើយអឺ....ចឹងលោកតាមានស្រុកកំណើតនៅឯណាដែរលោកតា?

ខ៖ បាទនៅស្រុកកោះធំខេត្តកណ្តាលយើងនឹងបាទ!

ក៖ ចាសលោកតា ហើយលោកតានៅភូមិឈ្មោះអីដែរលោកតា?

ខ៖ ភូមិកំណើតភូមិពោធិ៍បាន
នៅស្រុកកោះធំខេត្តកណ្ដាលតែមានគ្រួសារទៅនៅនឹងអឺ....ភូមិឬស្សី ឃុំកំពង់កុង
ស្រុកកោះដាច់ ខេត្តកណ្តាល!

ក៖ ចាសហើយចុះសព្វថ្ងៃលោកតាមានទីលំនៅៗឯណាដែរ?

ខ៖ សព្វថ្ងៃខ្ញុំស្នាក់នៅនឹងវត្ត(សំលេងរំខាន)!

ក៖ ចាសលោកតា វត្តនឹងឈ្មោះអីដែរលោកតា?

ខ៖ វត្តរង្សីហៅវត្តចិនដំដែកខាងជើង(សំលេងមនុស្សចាស់និយាយគ្នា)!

ក៖ ចាសលោកតា ហើយចុះទីតាំងវត្តនេះផ្ទាល់លោកតា?

ខ៖ បាទ?

ក៖
ទីតាំងវត្តនេះអឺ....ទីតាំងវត្តនេះផ្ទាល់លោកតាដូចជានៅអឺ....នៅភូមិនៅសង្កត់ណានៅខណ្ឌ
ណាដែរលោកតាៗអាចបញ្ជាក់បានដែរឬទេលោកតា?

ខ៖ នៅអឺ....សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជនីយភ្នំពេញ!

ក៖ ចាសអរគុណច្រើនលោកតាហើយអឺ....សព្វថ្ងៃលោកតាមានមុខរបរជាអីដែរលោកតា?

ខ៖ ខ្ញុំទទួលខាងផ្នែកជាអាចារ្យប្រចាំវត្តនេះម៉ងចៅ!

ក៖ ចាសលោកតា ហើយប៉ុន្មានឆ្នាំហើយដែលលោកតាធ្វើការងារនៅក្នុងវត្តនឹង?

ខ៖
ខ្ញុំនៅប្រហែលជាប្រាំពីរឆ្នាំហើយ(សំលេងមនុស្សនិយាយគ្នា)ខ្ញុំរាប់ទៅវាដើមប្រាំពីរឆ្នាំហើយ
ដែលមកនៅនឹងវត្តនឹង(គាត់មករស់នៅក្នុងវត្តរយះពេលប្រាំពីរឆ្នាំហើយ)!

កៈ ចាសលោតាចឹងលោកតាទទួលបានបទពិសោធន៍ច្រើនទាកទងនឹងការងារនៅក្នុងនឹងដែរ ចាសលោកតាហេតុអីបានជាលោកតាសំរេចចិត្តនៅក្នុងការធ្វើការងារជាអាចារ្យវត្តនៅនឹងដែរ លោកតា?

ខៈ
បាទខ្ញុំបានមើលឃើញថាក្នុងមួយរយៈកាលកន្លងមកដែលតារស់នៅខាងស្រុកកំណើតនឹង ឃើញថាប្របកមុខរបរអាជីវកម្មដើររកស៊ីលក់ដូរនឹងណាស់ហើយនឹងធ្វើស្រែចំការជាកសិករ បាទហើយដល់តែចូលវ័យចំណាស់បន្តិចមកឃើញថាកំលាំងរបស់ខ្ញុំនឹងក៏វាកាន់តែខ្សោយទៅ ហើយដែរចំណែកឯចំណេះដឹងជំនាញនឹងផ្នែកដែលយើងប្រើកំលាំងពលកម្មនឹងយើងវាមិន អាចធ្វើទៅបានដល់ចឹងទៅ
ខ្ញុំក៏នឹកឃើញថានៅមានចំណេះតិចតួចខាងផ្នែកព្រះពុទ្ធសាសនាដែរ(សំលេងមនុស្សចាស់និ យាយគ្នា)
ខ្ញុំក៏បានមករួមជាមួយថៅអធិការដែលព្រះអង្គគង់នៅប្រចាំនៅក្នុងវត្តរង្សីនឹងម៉ងណាស់ បាទទៅបំពេញផ្នែកសិក្សារបំពាក់បំប៉ន់ផ្នែកខាងអាចារ្យនឹងនៅក្រសួងធម្មការខេត្តគាត់បានដូ ចជាអឺ....ចេញវិញ្ញាប័ណ្ណអោយខ្ញុំបាទនឹងហើយទទួលស្គាល់ជាអាចារ្យសមាគមន៍ខ្មែរ!

កៈ ចាស លោកតា ហើយលោកតាមកនៅនឹងវត្តនឹងប៉ុន្មានឆ្នាំហើយលោកតាតាំងពីឆ្នាំណាមកលោកតា?

ខៈ (សំលេងមនុស្សនិយាយគ្នា) បានកន្លងមកប្រហែលជាប្រាំពីរឆ្នាំហើយ!

កៈ ២០១១ហ៎លោកតា?

ខៈ បាទប្រហែលជា២០១១នឹងហើយ!

កៈ ចាសលោកតាហើយទៅអឺ....អឺលោកតា កាលពីមុនលោកតាបានសិក្សាបានដល់កំរិតណាដែរ?

ខៈ ផ្នែកអក្សរសាស្រ្ត?

កៈ
ចាសលោកតាដូចជាអឺ....ការអប់រំទូទៅដូចជាថ្នាក់ទីមួយទីពីរពីបីរហូតដល់កំរិតការសិក្សានៅ ជំនាន់ដើមម៉ងាណាស់?

ខ៖
តាបានចូលសិក្សាតាំងពីតានៅវ័យអាយុ១០ឆ្នាំជាងកាលស្ថិតនៅក្នុងជំនាន់សម្ដេចព្រះសីហនុនឹងតាក្រខ្សត់ណាស់តែខិតខំត្រដររៀនសូត្រមករហូតបានដល់ថ្នាក់ទី៧ណាស់បាទថ្នាក់ទី៧នៅជំនាន់សង្គមចាស់បាទហើយរហូតមកដល់គេធ្វើរដ្ឋប្រហាតទំលាក់សម្ដេចព្រះសីហនុទៅក៏តាខកខានបានរៀនអស់ទៅហើយក៏បានចូលបួសៗបន្តទៅចឹងណាស់បួនជានេននៅវត្តនៅឯស្រុកឯណោះគេហៅថាវត្តនឹងថាវត្តពោធិ៍បាន
ហើយបន្តបន្ទាប់មកចូលមកក្នុងជំនាន់ពលពតមកទៀតមក នល់នល
បាទខ្ញុំធ្លាប់បានឆ្លងកាត់នល់នលនឹងម៉ោដែរ!

ក៖
ចាសលោកតាចឹងលោកតាធ្លាប់បានឆ្លងកាត់ការសិក្សាពីមុនមកចឹងលោកតាអាចនឹងអានអាចនឹងសសេរអីបានទាំងអស់ហើយមែនទេលោកតា?

ខ៖ បាទខ្ញុំអាចសសេរបានហើយអាចអានបានអានបាលីអីនឹងអាចអានបានដែរណាស់!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖
ហើយទៅលោកតាកាលដែរលោកតាសិក្សានឹងកាលនឹងនៅក្នុងវត្តឬក៏នៅក្នុងសាលាដែរលោកតា?

ខ៖ កាលនោះខ្ញុំរៀនអក្សរសាស្រ្តផ្នែកខាងសិក្សានឹងនៅសាលានៅសាលាក្នុងវត្តដែរណាស់សាលានឹងនៅក្នុងវត្តនឹងនៅឯស្រុកកំណើតនឹងឯងហើយរហូតដល់ពេលបួស តាមរយះអាចារ្យបង្ហាត់បង្រៀនផ្សេងៗទៀតដែរណាស់ បាទ ហើយអាចារ្យនឹងក៏ជាលោកដែរ(ជាព្រះសង្ឃ) បង្ហាត់ង្រៀនទើបបានខ្ញុំចេះដឹងមកខ្លះៗនឹង!

ក៖ ចាសលោកតា ចឹងលោកតាធ្លាប់បួសជាព្រះសង្ឃដែរន៍លោកតា?

ខ៖ បាទ ខ្ញុំបានបួសបានរយះពេល៧ព្រះវស្សាដែរៗ

ក៖ អូ.....ចាសលោកតា!

ខ៖ បាទ សាមណេរនឹងបាន៣ព្រះវស្សាហើយនឹងភិក្ខុនឹង៩ព្រះវស្សាដែរ!

ក៖ ចាសលោកតា ហើយហេតុអីបានជាលោកតាលាចាកសិក្ខាបទដែរលោកតាកាលនឹងណាស់លោកតា សឹកណាស់លោកតា?

ខ៖ អឺ.....មួយរយៈនឹងដាច់ដោយសារតែមាននល់នលជំនាន់នល់នលអឺ.....មិនអាន់បន្តទៅទៀតបានរហូលដល់ពេលនេះជំនាន់ពលពតនឹងចូលមកទៀតយើងដូចថាដាច់ព្រះដាច់អីអស់រលីងហើយ(នៅពេលឈានដល់ជំនាន់ពលពតព្រះសង្ឃហើយនឹងវត្តអារាមមួយចំនួនត្រូវបានគេកំទេចអស់)!

ក៖ អូ....ចាសលោកតា!

ខ៖ បាទ!

ក៖ ចាសលោកតា ខ្ញុំធ្លាប់លឺដែរចាស់ៗគាត់ធ្លាប់ប្រាប់!

ខ៖ បាទ ពលពតចូលមកគ្រប់គ្រងវិញ(សំលេងមនុស្សនិយាយគ្នាពីខាងក្រៅ)បន្ទាប់ពីពួកនលល់នលបានរលំរលាយទៅនឹងមក បាទ ហើយចឹងពលពតវាបំបាត់អស់រលីងហើយផ្នែកព្រះពុទ្ធសាសនាផ្នែកសាលារៀនអីនឹងគេបំបាត់ចោលអស់ហើយ!

ក៖ ចាសលោកតាត្រូវហើយ ចុះកាលនឹងឈ្មោះនៅកន្លែងវត្តនឹងឈ្មោះអីដែរលោកតា?

ខ៖ វត្តដែលខ្ញុំរស់នៅឯស្រុកនឹងហ្អែស?

ក៖ ចាសៗ!

ខ៖ កាលនឹងគេហៅថាវត្តពោធិ៍បាន ស្ថិតនៅក្នុងភូមិពោធិ៍បាន ឃុំពោធិ៍បាន ស្រុកកោះធំ!

ក៖ ចាសៗ លោកតាសព្វថ្ងៃមានក្រុមគ្រួសារហើយឬនៅលោកតា?

ខ៖ បាទ ខ្ញុំអឺ....គ្រួសារនឹងនៅយាយរបស់ខ្ញុំនឹងណាស់នៅ(ប្រពន្ធរបស់លោកតា) ហើយខ្ញុំមានកូនទាំងអស់បីនាក់!

ក៖ ចាសលោកយាយ ហើយចុះលោកយាយគាត់មានឈ្មោះអីដែរ?

ខ៖ លោកយាយគាត់ឈ្មោះយាយ ឆេង យ៉ុក!

ក៖ ចាសលោកតា!

ខ៖ គេចំណាំហៅថាយាយយ៉ុកៗចឹងណាស់!

ក៖ ចាសលោកតា លោកយាយគាត់ត្រូវជាភរិយារបស់លោកតា?

ខ៖ ហើយកូន....បាទៗគាត់ត្រូវជាភរិយារបស់ខ្ញុំ!

ក៖ ចាស លោកតាមានភរិយាតែម្នាក់នឹងទេន៍លោកតា?

ខ៖ កាលនេះខ្ញុំមានបងរបស់ប្រពន្ធសព្វថ្ងៃនេះមួយទៀតណាស់ ក៏ប៉ុន្តែគាត់ស្លាប់បាត់ទៅហើយណាស់ជួបគ្នានឹងបានតែកូនមួយហើយគាត់ក៏បានស្លាប់បាត់ទៅ!

ក៖ ចាសលោកតា ហើយកូនរបស់គាត់ម្នាក់នឹងឈ្មោះអីដែរ?

ខ៖ ឈ្មោះអឺ....ចាន់ណា បាទ!

ក៖ ចាសលោកតា ចុះលោកយាយវិញគាត់មានឈ្មោះអីដែរ?

ខ៖ អឺ....ប្រពន្ធមុននឹងហ្អែស?

ក៖ ចាសលោកតា!

ខ៖ បាទ ឈ្មោះណាន លោកយាយឆេង ណាន!

ក៖ លោកយាយឆេង ណាន ចាសលោកតាហើយចុះអឺ...លោកយាយប្រពន្ធក្រោយរបស់លោកតាហើយទៅគាត់មានកូនប៉ុន្មាននាក់ដែរលោកតា?

ខ៖ បាទគាត់បានកូនបួននាក់បន្តមកទៀតក៏ប៉ុន្តែកូននឹងនៅសល់តែពីរនាក់ទេបាទ កូនដូចថាគ្នាស្លាប់តាំងពីនៅតូចៗដែរណាស់!

ក៖ ចាសលោកតា ហើយពួកគាត់ស្លាប់ដោយសារអីដែរលោកតា?

ខ៖ បាទ?

ក៖ គាត់ស្លាប់ដោយសារមូលហេតុអីដែរលោកតា?

ខ៖ បាទថាម៉េច?

ក៖ គាត់ហេតុអីបានជាគាត់ស្លាប់ណាស់កូនលោកតាពីរនាក់នឹងណាស់?

ខ៖ អឺ....ជំងឺពីដើមដូចថាយើងគ្មានពេទ្យគ្មានម៉ច្បាស់លាស់ដូចសម័យឥលូវនឹងទេណាស់មើលតែតាមរយះគ្រូខ្មែរយើងនឹងគេហៅថាជំងឺ.....(សំលេងស៊ីផ្លេឡាន)បើពីដើមគេហៅថាជំងឺតេនតានុស បាទ....

ក៖ ចាសលោកតា!

ខ៖ គេហៅថាស្គន់ណាស់ បាទគេហៅថាស្គន់!

ក៖ ចាសលោកតា កូនលោកតាទាំងពីរនាក់នឹងតែម្តងលោកតាន៏?

ខ៖ បាទវារបៀងគ្នាកូនទាំងពីរនាក់នឹងណាស់រមៀងគ្នា(ប្រហាក់ប្រហែលគ្នា)!

ក៖ ហើយកាលនឹងពួកគាត់មានវ័យស្របារគ្នាដែរឬទេលោកតា ប្រហែលជាអាយុប៉ុន្មានដែរទៅ?

ខ៖ បាទបានអាយុបីខែ បួនខែនឹងបាទ អត់បានកន្លងឆ្នាំផងនឹង បាទ!

ក៖ អូ....សោកស្តាយមែនទែនណាស់លោកតា!

ខ៖ បាទ!

ក៖ ពួកគាត់មានឈ្មោះអីដែរលោកតាកូនរបស់លោកតាទាំងពីរនាក់នឹងណាស់?

ខ៖ បាទ អត់ទាន់បានដាក់ឈ្មោះអោយផង!

ក៖ អត់ទាន់បានដាក់ឈ្មោះអោយទៀត?

ខ៖ បាទ.....

ក៖ ចាសលោកតា ហើយចុះកូនពីរនាក់ទៀតដែលនៅរស់នឹងគាត់មានឈ្មោះអីដែរ?

ខ៖ ហើយដែលខ្ញុំនៅសល់កូនពីរនាក់នឹងកូនបងឈ្មោះ សូនី មួយ ម៉ាក សូនី បាទ ហើយកូនទីពីរប្រុសដែរឈ្មោះ ម៉ាក សូនឿន!

ក៖ ចាសលោកតា!

ខ៖ បាទប៉ុន្តែមានគ្រួសារអស់ហើយ!

ក៖ ចាសលោកតា ហើយចឹងកូនរបស់លោកតាសរុបទាំងអស់ដែលនៅរស់មានជីវិតនឹងទាំងអស់បីនាក់?

ខ៖ បាទ នៅមានកូនប្រពន្ធមុនមួយ!

ក៖ ចាសលោកតា!

ខ៖ បាទ ហើយប្រពន្ធខ្ញុំមុនក៏ត្រូវជាបងរបស់ប្រពន្ធខ្ញុំសព្វថ្ងៃនឹងដែរ!

ក៖ ចាសលោកតា ហើយអឺ....គាត់....ដូចជាកូនរបស់លោកតាស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខ៖ ស្រីតែមួយ នៅប្រុសពីរបាទ!

ក៖ ចាសលោកតាហើយពួកគាត់ទាំងអស់គ្នាបានរៀបអាពាហ៌ពិពាហ៌ហើយអស់ហើយឬនៅ?

ខ៖ បាទរៀបការអស់ហើយ!

ក៖ ចឹងលោកតាមានក្រុមគ្រួសារមានចៅហើយណាស់លោកតា?ខ

ខ៖ បាទ ខ្ញុំមានចៅ៦ហើយ(សំលេងរំខានពីខាងក្រៅ)កូនបីនាក់នឹងបានចៅ៦នាក់!

ក៖ ចុះកូនរបស់លោកតាទាំងបីនាក់ពួកគាត់មានការងារធ្វើអស់ហើយន៍លោកតា?

ខ៖ សុទ្ធតែជាកសិករទាំងអស់នឹងនាង កម្មកររោងចក្រអីនឹង ហើយបើកូនប្រុសៗនឹងធ្វើជាកសិករស្រែចំការមួយមានប្រពន្ធនៅកំពង់ស្ពឺ មួយមានប្រពន្ធនៅកំពត ស្រុកដងទងឯណោះ!

ក៖ ចាសលោកតា ហើយពេលមានបុណ្យទានអីម្តងៗគាត់មកនេះឬមួយក៏លោកតាត្រូវទៅស្រុក?

ខ៖ ពេលខែរដូវដូចជាចូលឆ្នាំអី កាន់បិណ្ឌភ្ជុំអីកូនមក គេមករកឪពុកម្តាយចឹងទៅ បាទទៅតាមប្រពៃណីរបស់យើងនឹងទៅគេមកជួបជុំឪពុកម្តាយបងប្អូនចឹងទៅរួចរាល់ចឹងទៅ ទើបបានគេនាំគ្នាត្រឡប់ទៅវិញទៅស្រុក ទៅផ្ទះគេវិញទៅ!

ក៖ ចឹងលោកតាត្រូវធ្វើដំណើរទៅជួបនឹងលោកយាយហ៎?

ខ៖ បាទខ្ញុំទៅញឹកញាប់ដែលពេលអត់សូវមានរវល់អីនៅក្នុងវត្តខ្ញុំទៅ ហើយបើមានរវល់អីក្នុងវត្តយើងនៅប្រចាំការនៅក្នុងវត្តនឹងម៉ងដូចខែបិណ្ឌភ្ជុំអីនឹងយើងត្រូវនៅនឹងដល់ហើយចឹងយាយគាត់មកនឹងដែរគាត់មានជំនាញខាងធម៌អារ្យខាងអៈរតនាព្រំអីចឹង ណាស់(អ្នកសូត្រព្រំពេលព្រះមន្តសម្តែងធម្មទេសនា) ព្រំនៅនឹងវត្តនឹងណាស់!

ក៖ ចាស!

ខ៖ បាទ គាត់មកនឹងរួមការងារដែរនឹងពេលផុតខែរវល់បានគាត់ទៅផ្ទះវិញ!

ក៖ ចាសៗ ចឹងលោកយាយសព្វថ្ងៃគាត់នៅតែម្នាក់ឯងឬក៏យ៉ាងណាលោកតា(សំលេងរំខានពីខាងក្រៅ0?

ខ៖ គាត់នៅជាមួយកូនមួយកូនបងប្រុសគេដែលថាឈ្មោះ សូនី នឹងណាស់នៅដេកជាមួយព្រោះវាឃើណាស់!

ក៖ ចាស!

ខ៖ ចឹងហើយគាត់ក៏ទៅនៅជាមួយកូននឹងនៅជាមួយកូននឹងមើលចៅពីរ!

ក៖ ចាស!

ខ៖ គាត់អត់សូវបាននៅជាប់នឹងវត្តទេ(សំលេងមនុស្សរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖ ចាស ចឹងហើយអឺ....កូនរបស់លោកតាគាត់អត់មានកូនណាដែលត្រូវបានស្លាប់នៅក្នុងជំនាន់ពលពតនោះទេន៏លោកតា?

ខ៖ កូនស្លាប់នៅក្នុងជំនាន់ពលពតតា....ដូចជាអត់មានទេចៅយើងបែកពលពតឆ្នាំ៧៩(ឆ្នាំ១៩៧៩) ហើយបានវាយកគ្រួសារ ដល់ចឹងយើងវាកន្លងផុតពលពតហើយណាស់!

ក៖ ចាសចឹងលោកតាកាល......

ខ៖ បើបងៗបានមានស្លាប់នៅក្នុងជំនាន់ពលពតនឹង!

ក៖ អូ....បងប្រុសហ៎?

ខ៖ បាទ បងប្រុស អឺ...បង...ប្អូន បងប្អូន បងថ្លៃអីស្លាប់អស់ហើយនៅសម័យនឹង!

ក៖ អូ....ចឹងលោកតាមានចាំឈ្មោះរបស់ពួកគាត់ដែរឬទេពួកគាត់មានឈ្មោះអីគេខ្លះទៅ?

ខ៖ បាទបងបង្អស់ ប៉ា យ៉េត ឈ្មោះប៉ា យ៉េត ហើយបងទីពីរ ឈ្មោះ ប៉ា ណាគ្រី ឈ្មោះប៉ា ណាគ្រី បាទហើយពួកគាត់សុទ្ធតែជាបងៗរបស់ខ្ញុំហើយបន្ទាប់បានខ្ញុំនឹងម៉ងនៅបីអ្នក!

ក៖ បងប្អូនរបស់លោកតាប៉ុន្មានអ្នកដែរ?

ខ៖ ស្រីតែមួយហើយប្រុសនឹងប្រាំមួយ(សើច)!

ក៖ (សើច) ខ្សត់ស្រីលោកតា!

ខ៖ បាទ កំសត់ស្រី!

ក៖ ចាស!

ខ៖ គាត់ចាស់ៗដែរហើយបងស្រីខ្ញុំនឹងគាត់៧០ជាង(បងស្រីរបស់លោកតាអាយុ៧០ឆ្នាំជាងហើយ)!

ក៖ ចាសលោកតា ហើយពួកគាត់ទាំងអស់គ្នានៅមានព្រះជន្មតើហីលោកតា?

ខ៖ បាទនៅគាត់រស់នៅ.....

ក៖ គាត់....

ខ៖ តាមជាមួយកូនចៅរបស់គាត់ណាស់!

ក៖ ចាស!

ខ៖ នៅតាមផ្ទះ!

ក៖ គាត់ខាងស្រុកនៅឯណាដែរលោកតា?

ខ៖ បាទគាត់នៅខាងពោធិ៍បាននឹងដែរ ស្រុកកំណើតនៅនឹង!

ក៖ ចាសៗ!

ខ៖ បាទទឹកដីកេរ្តិ៍កំណើតណាស់!

ក៖ ចាសលោកតា ហើយចុះឪពុកម្តាយរបស់លោកតាពួកគាត់មានឈ្មោះអីដែរ?

ខ៖ អឺ....ឪពុករបស់ខ្ញុំគាត់ឈ្មោះ ប៉ា យ៉ុំ!

ក៖ ចាស!

ខ៖ បាទ ម្តាយឈ្មោះ អ៊ូ សុទ្ធ!

ក៖ ចាស លោកតា!

ខ៖ បាទហើយចំណែកឪពុកគាត់បានស្លាប់តាំងពីអាយុ៧០គាត់៧៤នឹង បាទហើយម្តាយគាត់បានស្លាប់នៅអាយុ៨៧ឆ្នាំ!

កៈ ចាសអូ...សោកស្តាយមែនទែនគាត់ស្លាប់យូរហើយលោកតា?

ខៈ បាទយូរហើយ!

កៈ ប្រហែលជាប៉ុន្មានឆ្នាំហើយលោកតា?

ខៈ ប្រហែលជា១០ឆ្នាំ ទៅ១៥ឆ្នាំហើយ បាទ!

កៈ
ចាសហើយចុះលោកតាកាលពីសម័យពលពតណាស់លោកតាៗធ្លាប់បានឆ្លងកាត់មកនឹងតើលោកតាត្រូវបានគេជំលៀសទៅណាហើយគេអោយគេប្រើលោកតានឹងធ្វើអីខ្លះដែរ?

ខៈ
កាលពីសម័យពលពតដែលបានចូលមកបន្ទាប់ពីខ្ញុំបានឆ្លងកាត់ការសិក្សាសឹកពីបួសពីអីទៅនឹងតានៅមិនទាន់មានគ្រួសារទេ(សំលេងរំខានពីខាងក្រៅ)អឺ...ចូលគេអោយចូលទៅខាងកងយោធា ខាងយោធាឃុំណាស់ ខាងយោធាឃុំនឹងហើយបន្ទាប់មកបានគេបញ្ជូនអោយទៅនៅខាងផ្នែកស្រុក(សំលេងស៊ីផ្លេឡាន) ធ្វើជាយោធាស្រុកប៉ុន្តែខ្ញុំគេអោយធ្វើខាងពេទ្យកងទ័ពណាស់បាទនៅប្រចាំមន្ទីរអីនឹង(សំលេងរំខានពីខាងក្រៅ) មន្ទីរនៅស្រុកអីចឹងទៅនឹងនៅនឹងមន្ទីរពេទ្យកងទ័ពនឹងហើយបានពេលដែលទៅសមរភូមិបានគេដកទៅសមរភូមិទៅ គេអោយយើងទៅវ៉ៃនឹងសមរភូមិដែររហូតខ្ញុំនៅតែប្រចាំការធ្វើជាពេទ្យនៅតាមកងវីរៈសេនាតូចសេនានឹងរហូតមក ហើយនឹងនៅស្នាក់ការទៅខាងផ្នែកស្វាយរៀងឯណោះបាទនៅខាងស្វាយរៀង(សំលេងមនុស្សនិយាយគ្នា) អូររាំងឪឆ្លងកាត់រហូតដល់ទល់ដែនរហូតដល់បែកៗអាពតនឹងបានខ្ញុំមកវិញបានបកចូលមកផ្ទះវិញមកនៅក្នុងឆ្នាំ១៩៧៩!

កៈ ចាស(សំលេងមនុស្សនិយាយគ្នា) ហើយកាលនឹងលោកតានៅក្នុងសម័យពលពតនឹងលោកតាមានដែលឃើញអពតនឹងយកមនុស្សទៅស្លាប់នៅនឹងភ្នែកដែរឬទេ?

ខ៖ បាទ រឿងនឹងគឺវាពិតជាមានពិតប្រាកដមែនហើយ (សំលេងរំខានពីខាងក្រៅ) គេធ្វើទុក្ខធ្វើទារុណកម្មប្រជាជន យុវជន យុវនារីនឹងដូចថាលទ្ធិផ្ដាច់ការចំ(សំលេងមនុស្សនិយាយគ្នា)ប្រើអំណាចខុសអីឬក៏មិនខុសអីនឹងក៏វានៅចាំតែចាប់តែទោសកំហុសបានលេសយកទៅស្លាប់នឹងមិនថាចាស់មិនថាក្មេងមិនថាកុមារនោះទេ(សំលេងមនុស្សនិយាយគ្នា) ហើយកុមារអីនឹងសូម្បីតែកើតមកហើយនឹងក៏គេមានមណ្ឌលអោយមេដោះនឹងមើលទៅហើយចំណែកម៉ែឪនឹងគេយកទៅអោយធ្វើការងារអស់ហើយជីកប្រឡាយ វែកទឹកអី....វែកដីបាទឪពុកជូនណាទៅដកស្ទូងអីចឹងទៅ!

ក៖ ចាសចឹងកាលនឹងគេមានធ្លាប់ធ្វើបាបលោកតាដែរឬទេ?

ខ៖ ហើយចំពោះខ្ញុំៗនៅដាច់ខាងកងទ័ពគឺថាឃើញថាគេមានការយកចិត្តទុកជាមួយដែរណាស់ បាយទឹកអី (សំលេងឡាន) គេផ្គត់ផ្គង់អីបានគ្រប់គ្រាន់មិនអោយខ្វះខាតទេ!

ក៖ ចាស!

ខ៖ ប៉ុន្តែផ្ដោតសំខាន់ទៅលើកសិករសហករណ៍នៅក្រោយនឹងគឺថារស់នៅគឺវេទនាជាទីបំផុតស៊ីអត់ស៊ីឃ្លានណាស់(សំលេងមនុស្សនិយាយគ្នា) បាទបបតពោតក៏មានបបរសយើងនឹងក៏មានជូនណាទៅមួយវែកជូនណាទៅក៏ពីរវែកអីនឹងក៏មានដែរមួយផ្ទះនឹងនៅ៣០ទៅ៤០អ្នកចឹងទៅបើនៅខាងផ្នែកកងទ័ពនៅខាងសមរភូមិឃើញថាគេអោយហូបទៅតាមដំណើររបស់យើងគេអោយហូបឆ្អែតៗដែរណាស់!

ក៖ ចាស!

ខ៖ ចឹងបាទនឹងគេកំលាំងត្រៀមៗយកកំលាំង(សំលេងស៊ីផ្លេឡាន)ហើយពេលដែលគ្មានសង្គ្រាមអីគេអោយកងទ័ពនឹងធ្វើស្រែដែរគេចាប់យកកំលាំងធ្វើស្រែដកស្ទូង(សំលេងមនុស្សនិយាយគ្នា)យកស្រូវយកអង្ករនឹងដែរ(សំលេងស៊ីផ្លេឡាន) ប៉ុន្តែមិនអោយហូបគ្រប់គ្រាន់ទេ!

ក៖ ចឹងសម័យនឹងគេអោយលោកតានូវរបបអាហារឬក៏ជាបាយឬក៏ជាបបរដែរលោកតា?

ខ៖ (សំលេងមនុស្សនិយាយគ្នា) កាលដែលមិនទាន់បានចេញមកពីសមរភូមិគេអោយមកជាបបរដែរជាបបរចឹងទៅ ដល់ពេលទៅសមរភូមិទៅគេអោយយើងហូបបាយ!

ក៖ អឺម ចាស!

ខ៖ បាយខ្ទុក បាយកញ្ចប់សង្រែកចឹងទៅមានកងចល័តនារីៗកុមារអីនឹងវែកយកទៅអោយនៅនឹងសមរភូមិនឹងគេចែកណាស់គេចែករបបអោយ(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា ចឹងកាលនឹងពិបាកណាស់លោកតាស្តាប់មើលទៅ?

ខ៖ អូ....វេទនាណាស់ចៅហើយ អ្នកដែលមិនធ្លាប់ឆ្លងកាត់អត់ដឹងថាសង្គមពលពតនឹងបែបណាទេ ប៉ុន្តែអ៊ុំឆ្លងកាត់មករស់(សំលេងមនុស្សនិយាយគ្នា)អ្នកដែលនៅរស់សេសសល់នឹងសុទ្ធតែអ្នក...បើនិយាយនៅសម័យបច្ចុប្បន្នសុទ្ធតែជាអ្នកដែលមានបុណ្យកុសលនឹងម្យ៉ាងទៅ ហើយជាអ្នកដែលមានភ័ព្វសំណាងនឹងមួយទៅនឹងហើយអ្នកដែលអាចរស់អាចសល់បានណាស់បាទ ចឹងដូចគេថាធ្មេញរនាស់នឹងរាស់ខ្មេចអស់រលីងហើយ នៅសេសសល់មួយនឹងសុទ្ធតែអ្នកដែលមានភ័ព្វសំណាងខ្លាំងណាស់(សំលេងមនុស្សនិយាយគ្នា)ហើយបើដូចមួយគ្រួសារខ្ញុំនឹងប្រាំពីរប្រាំបីនាក់ឃើញនៅសល់បីនាក់ហើយបើបងថ្លៃបងអីនឹងយកទៅទាំងកណ្តាលយប់ទាំងកណ្តាលអាធ្រាតមិនដឹងថាហេតុផងខុសអីផងដូចវាធ្វើទុក្ខធ្វើបាបយើងខ្លាំចឹងណាស់ហើយចំពោះដូចរូបអ៊ុំវិញក៏ពៀមៗនឹង(រៀបនឹង)គេយកទៅកន្លែងធ្វើទុក្ខធ្វើទោសនឹងដែរតែប៉ុន្តែដូចថាវាចៃដន្យក៏ថាបានដូចថាគេអាចរំលងយើងបានចឹងណាស់ចឹងបានគេយកទៅប្រើតាមដំណើរនឹងទៅតាមសមរភូមិអីចឹងទៅ មានចំណេះចំនាញខាងពេទ្យអីនឹង....ដល់នេះទៅដល់នេះបែកហើយនឹងបានរួចខ្លួននឹងបានរត់មកផ្ទះវិញមកបាទ!

ក៖ ចាសលោកតា! ហើយអឺ....ជីវិតរបស់លោកតានៅក្នុងសម័យពលពតនឹងលោកតាមានការចងចាំអីខ្លាំងជាងទិដ្ឋភាពអីគេខ្លះ?

ខ៖
ចំនុចសំខាន់របស់ខ្ញុំគឺខ្ញុំបានចេញតែពីរគ្រួសារឪពុកម្ដាយចេញពីបួសនឹងទៅគឺខ្ញុំរស់នៅក្នុង(សំលេងមនុស្សនិយាយគ្នា)ជួរកងទ័ពរហូតម៉ងខ្ញុំគឺផ្នែកពេទ្យនឹងគឺផ្ដោតអារម្មណ៍ជាប់ម៉ងផ្នែកការងារនៅសមរភូមិអីចឹងបាទហើយខាងផ្នែកស្រែចំការកសិករនៅខាងនោះខ្ញុំអត់បានឆ្លងកាត់ទេចុះកាលនោះពេញវ័យយុវជន!

ក៖ ចាស!

ក៖ គេហៅថាយុវជនពេញកំលាំង(សំលេងមនុស្សនិយាយគ្នា)ដល់ពេលតែបែកហើយ៧៩(បែកពលពតនៅឆ្នាំ១៩៧៩) ទៅបានបកមកជួបជុំគ្រួសារម៉ែឪរកប្រពន្ធស្ដីដណ្ដឹងស្អីអីអោយនឹងទៅ!

ក៖ អូ...

ខ៖ ហើយការផ្ដោតភ្ជាប់របស់ខ្ញុំនៅក្នុងសង្គមគឺយើងបានធ្វើជាកងទ័ពនឹងទេ!

ក៖ ចាសលោកតាហើយអឺ....កាលនឹងលោកតាធ្វើការប៉ុន្មានម៉ោងដែរ?

ខ៖ អត់មានរាប់ពីម៉ោងទេបាទអត់និយាយពីម៉ោងបើគេត្រូវការយប់ៗត្រូវការថ្ងៃៗព្រឹកល្ងាចមិនថាកំពុកដេកកំពុងរងាអីទេស្មើណាក៏ដោយអោយតែមានបទបញ្ជារគឺត្រូវតែទៅហើយ(សំលេងមនុស្សនិយាយគ្នា)អត់មានកំណត់ម៉ោងម៉ង(សើច)!

ក៖ ចាស!

ខ៖ បាទគឺវាចឹងណាស់ចៅ!

ក៖
ចាសចឹងអឺ...កាលពីមុនមកតើលោកតាធ្លាប់ឆ្លងកាត់សម័យពីមុនទៀតមានសម័យអីគេខ្លះដែរលោកតា?

ខ៖ អឺ....ខ្ញុំទាន់ទីមួយនោះគឺទាន់(សំលេងរំខានពីខាងក្រៅ)ជំនាន់ចម្ដេចសីហានុនឹងម៉ងណាស់ជំនាន់សម្ដេចនរោត្តមសីហានុប៉ុន្នឹងកាលនឹងខ្ញុំនៅវ័យតូច

នៅឡើយទេ១០អឺ...ឆ្នាំ៧០(ឆ្នាំ១៩៧០) ឆ្លងកាតរហូតមកដល់៧៥នឹង(ឆ្នាំ១៩៧៥) បានទាន់ជំនាន់លន់នលៗនឹងខ្ញុំក៏នៅស្ទើរយុវជននៅឡើយទេនៅជាកុមារនៅរៀនសាលា(សំលេងរំខានពីខាងក្រៅ)
បានឈានចូលមួយជំណាក់ទៀតមកដល់ជំនាន់ពលពតខ្ញុំបានរៀនដល់ថ្នាក់ទី៧សង្គមចាស់នឹងណាស់បានដាច់ការសិក្សារៀនសូត្រទាំងអស់នឹងពលពតដាក់ផែនការណ៍ផ្សឹកលោក(ចាប់ព្រះសង្ឃផ្សឹក)សាលារៀនអីរិន(ភាសាតំបន់) បិទអស់!

កៈ ចាស!

ខៈ ហើយក៏អត់បានសិក្សាអីបន្តទៅទៀតទេ បង្កើតជាសហករណ៍ជាអីយកកំលាំងបំរើការងារអោយគេនឹង!

កៈ ចាសលោកតា!

ខៈ បាទហើយបានបន្ទាប់មកបានធ្លាក់មកដល់បន្ទាប់ពីពលពតនឹងមកបានអឺ....(សំលេងរំខានពីខាងក្រៅ)
សម្តេចតេជោនឹងគាត់បានកើនកងទ័ពវាយរំដោះប្រជាជនពីពលពតនឹងមកទៀតមកបានយើងបានរួចខ្លួនគ្រប់គ្នាមកនឹងណាស់
នឹងប្រវត្តិដែលធ្លាប់បានឆ្លងកាត់មកគឺខ្ញុំបានដឹងប៉ុន្នឹងហើយបើកាលជំនាន់ឥស្សរអីនឹងក៏ខ្ញុំអត់ទាន់ដែរខ្ញុំ អើ...ដូចថាទាន់បំបេះៗនឹង(សើច)(លោកតាទាន់ចុងក្រោយជំនាន់ឥស្សរនឹង!

កៈ (សើច) ចាស!

ខៈ គ្រាន់បានតែទាន់បំបេះៗនឹងឃើញប៉មឃើញទួលគេកន្លែងទីតាំងរបស់ពួកឥស្សរនឹងណាស់ប៉ុន្តែយើងកើតអត់ទាន់ទេ បាទមកទាន់ច្បាស់ត្រឹមនឹងសម្តេចព្រះសីហនុទ្រង់គ្រប់គ្រងមក!

កៈ កាលជំនាន់នឹងលោកតាមានការងារឬក៏មុខរបរជាអីដែរ?

ខៈ អត់នៅជាកុមារ....

កៈ នៅជាកុមារ!

ខ៖ រស់នៅក្នុងបន្ទុករបស់ឪពុកម្ដាយចឹងណាស់កាលនឹងណាស់!

ក៖ ចាស!

ខ៖ យើងអាចរស់នៅជាមួយនឹងឪពុកម្ដាយណាស់កាលនឹងណាស់!

ក៖ ចាស! ចឹងពេលដែលពេលមុនដែលលោកតានៅក្មេងៗលោកតាមានធ្លាប់មានក្ដីស្រម៉ៃថាលោកតាចង់ធ្វើអីនៅពេលដែលធំឡើងណាស់លោកតា?

ខ៖ ដោយការស្រមើស្រម៉ៃរបស់ខ្ញុំកាលនឹងគឺខ្ញុំរស់នៅក្នុងបន្ទុកម៉ែឪហើយខ្ញុំក៏មានលក្ខណដែលគេហៅថាពិការណាស់ ពិការដៃពិការជើងដោយសារតែមានជំងឺរោគាពីតូចមកសម័យនេះគេហៅថាជំងឺស្វិតដៃស្វិតជើងដល់ចឹងឪពុកម្ដាយខ្ញុំគាត់ផ្ដេកផ្ដួលផ្ដោតតែម្យ៉ាងគឺផ្ទង់អោយខិតខំរៀនសូត្រដើម្បីក្រែងលោថាបានចំណេះចំនាញមានមុខរបរការងារមន្ត្រីរាជការអីនឹងគេចឹងទៅណាស់តែវាមិនបានសំរេចទេណាស់ដោយសារតែមានសង្គ្រាមរាំងស្ទះធ្វើអោយដំណើរការសិក្សានឹងបានចប់ត្រឹមថ្នាក់ទី៧នឹងទៅ!

ក៖ ចាសលោកតា!

ខ៖ ដាច់ការសិក្សាពីត្រឹមនឹងរហូតមកណាស់!

ក៖ ចាសឃើញថាគួរអោយសោកស្ដាយមែនទែនណាស់លោកតា!

ខ៖ បាទ!

ក៖ ចាសហើយលោកតាកាលនឹងគេអត់មានបង្រៀនពីភាសាន៍លោកតាន៍?

ខ៖ បាទ?

ក៖ គេអត់មានរៀនភាសាបរទេសទេហ៎?

ខ៖
ទេកាលនឹងបើយើងនៅរៀនបឋមសិក្សាឧត្តមសិក្សាឡើងទៅដល់ថ្នាក់ទី៧នឹងត្រូវប្រលងចូលថ្នាក់ទី៦គេហៅថាសាលាកិលេស
ពីដើមណាស់សាលាកិលេសកាលនឹងគេចូលរៀនបរទេសភាសា(នៅពេលដែលគេរៀនដល់ថ្នាក់ទី៧នោះគេត្រូវប្រលងចូលថ្នាក់ទី៦ ហើយថ្នាក់ទី៦នឹងគេមានបង្រៀនភាសាបរទេស)នឹងហើយរៀនចំណេះជំនាន់ផ្សេងៗរៀនគណិតរៀនអីៗផ្សេងៗទៀតហើយបើសិនជាថ្នាក់ទី១១ ថ្នាក់ទី១២ឡើងទៅយើងរៀនជាអក្សរសាស្ត្រ អឺ....តាំងពីស្រះអ ស្រះអា ក ខ អីចឹងទៅណាស់ចេះតែបំបែកលេខបូកដក់គុណចែកនឹងទៅណាស់(សំលេងស៊ីផ្លេឡាន)យោងទៅតាមវិជ្ជាជីវះដែលគ្រូវបង្ហាត់បង្រៀនពីជំនាន់សង្គមចាស់នឹងមកនឹង!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖
អ៉ឺម....កាលនឹងលោកតាមានបទពិសោធន៍អស្ចារ្យមែនទែនលោកតា(សំលេងស៊ីផ្លេឡាន)មានការតស៊ូទាំងជីវិតការសិក្សាហើយកាលនឹងលោកតាអឺ....បានសិក្សានឹងដោយសារតែមាននអឺ...ឪពុកម្ដាយាគាត់ជាអ្នកជំរុញអោយទៅរៀនន៍លោកតា?

ខ៖
បាទៗមានឪពុកម្ដាយជាអ្នកនាំមុខជាអ្នកដោះស្រាយសព្វយ៉ាងណាស់គាត់មិនសូវបានប្រើខ្ញុំអោយធ្វើការងារស្រែចំការនោះទេគាត់ថានឹកឃើញថាខ្លួនពិការអីចឹងណាស់
ចង់អោយបានចេះដឹង!

ក៖ តែឥលូវនឹងលោកតាជំងឺនឹងគឺជាហើយ?

ខ៖
បាទនេះជំងឺនឹងរោគនឹងវាបើវាកើតនៅនឹងខ្លួនហើយៗណាស់ជំងឺស្វិតដៃស្វិតជើងនឹងចឹងយើងទទួលផលមកប៉ុន្នឹងមកទៅតាមចំណេះចំនាញរបស់យើងនឹងមកធ្វើអីបានមកធ្វើនឹង(សំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា!

ខ៖ បានមកធ្វើជាអាចារ្យនឹងអីចឹងទៅណាស់!

ក៖ ចាសលោតា!

ខ៖ បាទបានខ្ញុំនឹងមករស់នៅស្នាក់នៅជាមួយនឹងវត្តលោក!

ក៖ ចាស ចឹងកាលនឹងមិនមកអីកំណើតទេណ៎លោកតាជំងឺនឹងគឺកើត.....

ខ៖ អត់ទេជំងឺនឹងគឺកើតបើតាមដឹងមកឪពុកម្ដាយគាត់នេះមក កើតមកបានមួយយប់អឺ....មិនទាន់បានមួយខួបស្រួលបួលផងនឹងក៏ចាប់ផ្ដើមគេហៅថាជំងឺគ្រុនក្ដៅណាស់ខ្លះគេថាគ្រុនសន្ធំណាស់ហើយយើងពីមុនវាអត់សូវមានអឺ....ពេទ្យម៉អីទេប្រើតែគ្រូខ្មែរថ្នាំខ្មែរនឹងនឹងរឹតដៃរឹតជើងអីចឹងទៅតែមិនបានមានថ្នាំអីដូចសម័យនេះនោះទេ(សំលេងមនុស្សនិយាយគ្នា)ទាញ!

ក៖ ចាសលោកតា!

ខ៖
ទាល់តែធ្លាក់ទៅចឹងណាស់(កាលដែលលោកតាឈឺនឹងមិនបានមានពេទ្យពិនិត្យមើលត្រឹមត្រូវនោះទេចឹងហើយទើបធ្វើអោយលោកតាស្វិតដៃស្វិតជើងតាំងពីតូចមក)
ម៉ាៗស្វិតដៃជើងនឹងវាអត់មានពេទ្យអីអោយជំនាញជំនាន់ដូចឥលូវនឹងទេ!

ក៖ ចាសកាលនឹងលោកតាដឹងដែរន៍ដឹងថាឈឺចឹង....

ខ៖ ខ្ញុំអត់ដឹងទាល់តែម៉ែឪនិយាយប្រាប់តើ!

ក៖ (សើច) ព្រោះអីកាលនឹងនៅតូច!

ខ៖ នៅតូចដឹងថាខ្លួនពិការតាំងពីតូចមកដែរប៉ុន្តែអត់ដឹងថាយើងឈឺរបៀបម៉េចៗនឹងណាស់ យើងអត់ទាន់មានវ័យចងចាំនឹងទេ!

ក៖ ចាស!

ខ៖
ឈឺតាំងពីប្រាំពីរប្រាបីខែមកគិតមើលហើយដល់យើងទំរាំនឹងដឹងក្តីវាចូលថ្នាក់ដល់បីឆ្នាំបួនឆ្នាំយើងមានការចងចាំតិចៗហើយណាស់!

ក៖ ចាស!

ខ៖ បាទៗ
រហូតមកទល់នឹងធំបានដឹងអូ....ខ្លួនតាពិការមានជំងឺចេះៗតាមរយះម៉ែឪគាត់និយាយទេ!

ក៖
ចាសចុះក្នុងជីវិតរបស់លោកតាតើតាមានបទពិសោធន៍ជីវិតលំបាកអីគេខ្លះឬក៏អាក្រក់ដែលលោកតាគិតថាធ្វើអោយជីវិតរបស់លោកតាចងចាំជាងគេនៅក្នុងចិត្តណាស់លោកតា(សំលេងមនុស្សនិយាយគ្នា)?

ខ៖
បើតាមនៅក្នុងជីវិតរបស់ខ្ញុំៗបានទទួលស្គាល់ថាធ្វើម៉េចបើយើងកើតមកនៅក្នុងលក្ខណខ្វះខាតដូចថាក្រីក្រហើយជីវភាពក៏ឃើញថាវាមិនជិតដល់ដូចគេដូចឯងដល់ចឹងក៏ឃើញថាវ័យវាចូលមកដល់វ័យដែលវាចំណាស់ប៉ុន្នេះទៅហើយវាមិនមានអីដែលសៅម៉ងក្នុងចិត្តទៀតនោះលះបង់តែម្យ៉ាងនោះគឺខិតខំបំពេញបុណ្យកុសលនឹងម្យ៉ាងទៅ
ចង់បានបុណ្យកុសលដូចថាយើងជាអ្នកកាន់ព្រះពុទ្ធសាសនាយើងជឿរជាក់ថាវាអាចមានជាតិមុខ!

ក៖ ចាស!

ខ៖ បាទ!

ក៖ ធ្វើអំពើល្អ បានល្អ!

ខ៖
បាទបើយើងខំសាងអំពើល្អសេចក្តីល្អចឹងទៅតាបានមកនៅក្នុងវត្តវ៉ាដឹងនាំពុទ្ធបរិស័ទសមាទានសីលបុណ្យទានតូចធំអីចឹងទៅណាស់ចៅ!

ក៖ ចាសលោកតា!

ខ៖ ដូចថាយើងតាំងចិត្តតែម៉្យាងដូចថាតាំងចិត្តធ្វើតែសេចក្ដីល្អអំពើល្អ សន្សំយកកុសលផងបុណ្យអីចឹងទៅណាស់!

ក៖ ចាសលោកតា(សំលេងរំខានពីខាងក្រៅ)!

ខ៖ ហើយការគិតនឹងផ្សេងក្រៅពីនឹងទៀតដូចថាវាហួសពេលនឹងគិតហើយ(សំលេងរំខានពីខាងក្រៅ)ដូចថាយើងវាចំណាស់នេះទៅហើយណាស់៦០ឆ្នាំប្លាយហើយ៧០ឆ្នាំថ្ងៃនេះថ្ងៃស្អែកហើយណាស់ចឹងហើយយើងមានតែផ្លូវដែលយើងឈានទៅសំរាប់ភពខាងមុខនេះឆាប់ៗនេះនឹងឯង!

ក៖ ចុះលោកតាសំរាប់បទពិសោធន៍ជីវិតរបស់លោកតាដែលធ្វើអោយលោកតានឹកឃើញមកធ្វើអោយលោកតាមានការសប្បាយចិត្តមានដែរឬទេ?

ខ៖ មាននៅពេលដែលនឹកឃើញផ្លូវល្អដល់ពេលចឹងទៅយើងអាចមានសណ្ដានចិត្តថាដូចថាមានកំលាំងចិត្តៗ(សំលេងរំខានពីខាងក្រៅ) តស៊ូបន្តទៅទៀតធ្លាប់ឆ្លងកាត់ការលំបាកវេទនាខ្លាំងអស់សង្ឃឹមដែរនៅក្នុងជីវិតប៉ុន្តែតានៅមានទឹកចិត្តមួយថាតស៊ូទៀតបន្តទៅទៀតដរាបណានៅមានជីវិតយើងត្រូវតែតស៊ូដោះស្រាយវាដើម្បីជីវភាពណាស់បាទ ដើម្បីឆ្លងកាត់ផ្នែកជីវភាពដែលលំបាកលំបិនក្រីក្រកំសត់ណាស់កាលនឹងណាស់តែឥលូវនេះឃើញថាយើងនឹងក៏បានឆ្លងកាត់វាមកអស់ហើយដែរការដូចថាយើងវាដោះស្រាយតែខ្លួនឯងម្នាក់តែម្ដងហើយនៅសល់តែពេលជរាទៅទេដេកជរាទៅអានឹងចាំគិតតទៅទៀតបើអាចនៅរស់ថ្នាក់នៅនឹងវត្តវ៉ាបានចេះតែនៅសិនទៅ!

ក៖ ចាស ចុះលោកតាអាចរកប្រាក់ចំណូលបានប៉ុន្មានដែរក្នុងដូចថាការងារមុខរបរមួយនឹង?

ខ៖ តាដូចថាអត់កំណាត់ទេក្មួយ(សំលេងមនុស្សនិយាយគ្នា) អត់មានកំណត់បានដូចថាអឺ....ក្នុងខែនេះបានណោះខែនោះបានប៉ុណោះអឺអត់នោះទេតាមជាក់ស្ដែងថ្ងៃណាដែលពុទ្ធបរិស័ទគេមកអញ្ជើញទៅចឹងទៅបុណ្យទានអីគេជូនមកតិចតួចអី៥០០

០០៛ ៥០០០០៛ ២០០០០៛ ៣០០០០៛ ប្អូនដប់ម៉ឺនអីចឹងទៅណាស់តាមបុណ្យតូចធំអីចឹងទៅ(សំលេងមនុស្សនិយាយគ្នា)!

ក៖ ចាសលោកតា!

ខ៖ ហើយបើផុតពីនឹងទៅត្រូវទំនេរសំរាកកនមើលសៀវភៅចឹងទៅ!

ក៖ (សើច) ចាសលោកតា ចាសហើយអឺ(សំលេងរំខានពីខាងក្រៅ)....មួយខែលោកតាអាចនឹងអឺ...សន្សំលុយបានប៉ុន្មានដែរលោកតា?

ខ៖ វា...(សំលេងរំខានពីខាងក្រៅ)ដូចខ្ញុំបានជំរាបពីខាងដើមមិញចឹងណាស់វា.....

ក៖ ដោយខែ.....

ខ៖ វាដោយខែ(សំលេងរំខានពីខាងក្រៅ)បើសិនជាដល់រដូវបុណ្យទានអីទៅដូចជាខែភ្ជុំដូចចូលឆ្នាំអីបាទចំណូលយើងអាចនឹងរកចូលបានក្រាស់ក្រែងបាទ បើថាអត់ទេអឺ....ជួនកាលនឹងក៏លោកហៅទៅសូត្រមន្តទៅ(សំលេងរំខានពីខាងក្រៅ)សង្ឃាទានអីចឹងទៅមួយខែនឹងបានតែពីរដងបីដងអញ្ចឹងទៅមិនបានច្រើននោះទេ!

ក៖ អ៊ឹម....ចាសលោកតា ចឹងលោកតាមានពាក្យពេចន៍អីជាចុងក្រោយដើម្បីផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយជាពិសេសកូនចៅរបស់លោកតាដូចជាកូនចៅទួនចៅលួតអីដែលពួកគាត់បានស្តាប់សំលេងរបស់លោកតាថ្ងៃនេះណាស់លោកតា?

ខ៖ បាទយល់ហើយណាស់ក្មួយបាទ ឃើញថាចឹងបានថាដំណើរជីវិតអឺ....របស់តារបស់អឺ....អ៊ុំនឹងកូនចៅចៅទួនក្រោយៗនឹងអាចយល់អាចដឹងហើយថាជីវប្រវត្តិឆ្លងកាត់ជាច្រើនជំនាន់មកហើយនឹងក្នុងរយះកាលមនុស្សដែលមានអាយុ៥០ទៅ៦០ឆ្នាំហើយនឹងបានទៅជួបប្រទះនឹងផ្លូវដែលតាធ្លាប់បានឆ្លងកាត់មកនឹងណាស់បានហើយក៏បញ្ជាក់ដែរថាមិនបានសុខមិនបានស្រួលមិនបានសំបូរសប្បាយទេសង្គមខ្លះបានតែបីឆ្នាំបួនឆ្នាំក៏ប្តូរទៅជាសង្គមមួយផ្សេងទៀតហើយដល់ខ្លះទៀតមិនបាននឹងន៏ដូចសង្គមុយើងបច្ចុប្បន្ននេះទេដូចថាយើងបានសុខសប្បាយយូរណាស់ចឹងកូនចៅជំនាន់ក្រោយបើ

អាចបានលឺសូវនូវជីវប្រវត្តិដែលខ្ញុំបានសំភាសន៍ជាមួយក្មួយស្រីនឹងណាស់បាទនៅក្នុងឪកាស វេលានឹងក៏ដូចជាបានជ្រាបមកតាមនឹងថាខ្ញុំធ្លាប់បានឆ្លងកាត់មកបីបួនជំនាន់ បី បួន ប្រាំជំនាន់ទៅហើយតាមមើល(សំលេងរំខានពីខាងក្រៅ)
ចឹងសេចក្តីអធិប្បាយរបស់ខ្ញុំមានតែប៉ុន្នឹងទេចឹងណាស់!

កៈ
ចាសៗសុំអរគុណច្រើនលោកតាហើយក៏សុំជូនពរលោកតាមានសុខភាពល្អមានអាយុវែងហើយនឹងជូនពរអោយក្រុមគ្រួសាររបស់លោកតាតាមសុភមង្គលក្នុងក្រុមគ្រួសារណាស់លោកតា!

ខៈ បាទ សាធុៗៗ!

កៈ ចាសសុំអរគុណលោកតា!